ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ៣១២៨២ អពដ

# សេចក្តីបំភ្លឺ

ថ្មីៗនេះ អគ្គនាយកដ្ឋានពន្ធដារសង្កេតឃើញថា សារព័ត៌មានអនឡាញមួយចំនួន ក៏ដូចជាបណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុក ដែលបានដកស្រង់ព័ត៌មានមកចុះផ្សាយថា រថយន្តដូចគ្នា វាយតម្លៃខុសគ្នា ដែលធ្វើឱ្យរដ្ឋបាត់ចំណូលពន្ធនាំចូល និងពន្ធផ្លូវរាល់ឆ្នាំ ដោយបានលើកឡើងថា មានភាពមិនប្រក្រតីនៅក្នុងការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៦ ចំពោះរថយន្ត TOYOTA HIACE ចំនួន ០២ គ្រឿង ដែលមានកម្លាំងម៉ាស៊ីនស្មើគ្នា មានទំហំស៊ីឡាំងប៉ុនគ្នា ប៉ុន្តែឆ្នាំផលិតខុសគ្នា (ឆ្នាំ២០១៥ និងឆ្នាំ២០១៦) ដោយតម្រូវឱ្យបង់ពន្ធក្នុងទំហំទឹកប្រាក់ខុសគ្នា គឺមួយគ្រឿងត្រូវបង់ប្រាក់ពន្ធចំនួន ២០០ ០០០៛ ខណៈដែលរថយន្តមួយគ្រឿងទៀត ត្រូវបង់ពន្ធចំនួន ៦០០ ០០០៛ ។

អគ្គនាយកដ្ឋានពន្ធដារសូមធ្វើការបំភ្លឺជូនសាធារណជនទាំងអស់ មេត្តាជ្រាបថា ផ្អែកតាមប្រការ ៩ នៃប្រកាសលេខ ៧១០ សហវ.ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចែងថា *"រថយន្តដឹកទំនិញធុនតូចមានទ្វារ ៤ (PICK UP) ត្រូវបានចាត់ទុកជារថយន្តទេសចរណ៍ ចំពោះរថយន្តមានអាយុកាលគិតពីឆ្នាំផលិតដល់ ០៥ ឆ្នាំ ត្រូវបង់ពន្ធតាមទំហំស៊ីឡាំង ដូចមានចែងក្នុងឧបសម្ព័ន្ធ II ភ្ជាប់ជាមួយប្រកាសនេះ។ ត្រូវបានចាត់ទុកជារថយន្តដឹកទំនិញធុនតូច មានទម្ងន់សរុបដល់ ៣តោន នៅពេលដែលរថយន្តនេះមានអាយុកាលគិតពីឆ្នាំផលិត លើសពី ០៥ឆ្នាំ ត្រូវបង់ពន្ធតាមទម្ងន់ផ្ទុក ដូចមានចែងក្នុងឧបសម្ព័ន្ធ I"*។ ចំណុច ១ នៃឧបសម្ព័ន្ធ I ចែងថា ប្រាក់ពន្ធត្រូវបង់ចំពោះរថយន្តដឹកទំនិញមានទម្ងន់សរុបដល់ ៣តោន គឺ **២០០ ០០០**៛ ខណៈឧបសម្ព័ន្ធ II ចែងថា ប្រាក់ពន្ធត្រូវបង់ចំពោះរថយន្តទេសចរណ៍ មានទំហំស៊ីឡាំងលើសពី ២០០០ ស.ម$^{៣}$ ដល់ ២ ៩០០ ស.ម$^{៣}$ មានអាយុដល់ ៥ឆ្នាំ គឺ **៦០០ ០០០**៛។

យោងទៅតាមប័ណ្ណសម្គាល់យានយន្តចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៦ របស់មន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តសៀមរាប ដែលផ្តល់ដោយអ្នកជាប់ពន្ធ ភ្ជាប់ជាមួយលិខិតប្រកាសបង់ពន្ធ បង្ហាញថា រថយន្តម៉ាក TOYOTA HIACE ពាក់ស្លាកលេខ សៀមរាប 2B-9906 គឺជាប្រភេទរថយន្ត**ដឹកទំនិញធុនតូច PICK UP**។ ជាក់ស្តែង រថយន្តនេះជាប្រភេទរថយន្តទេសចរណ៍ ដែលត្រូវបង់ពន្ធចំនួន ៦០០ ០០០ ៛ ព្រោះថា÷ ១-)មិនមែនជាប្រភេទ PICK UP ប៉ុន្តែស្ថាប័នជំនាញកំណត់ថាជាប្រភេទ PICK UP, ២-) មានអាយុកាលក្រោម ០៥ឆ្នាំ ព្រោះផលិតឆ្នាំ២០១៦។ នេះអាចជាការភាន់ច្រឡំដោយប្រការណាមួយរបស់ស្ថាប័នជំនាញក្នុងការចេញប័ណ្ណសម្គាល់យានយន្ត ដែលនាំឱ្យចំនួនប្រាក់ពន្ធត្រូវបង់ មិនត្រឹមត្រូវផងដែរ។

ផ្អែកលើនិត្តិភាពច្បាប់ យថាប្រភេទរថយន្ត (PICK UP) ទ្វារ ៤ អាយុលើសពី៥ឆ្នាំ ដែលត្រូវចាត់ទុកថាជារថយន្ត **ដឹកទំនិញធុនតូច មានទម្ងន់ផ្ទុកដល់ ៣តោន** គឺត្រូវបង់ពន្ធចំនួន **២០០ ០០០**៛។ ដូច្នេះ ការកំណត់ប្រាក់ពន្ធត្រូវបង់ចំពោះរថយន្តខាងលើនេះ គឺដោយសារតែក្នុងប័ណ្ណសម្គាល់យានយន្តចែងថាជាប្រភេទរថយន្តដឹកទំនិញធុនតូច PICK UP។

អគ្គនាយកដ្ឋានពន្ធដារសូមជម្រាបជូនសាធារណជនមេត្តាជ្រាបផងដែរថា អគ្គនាយកដ្ឋានពន្ធដារវាយតម្លៃប្រាក់ពន្ធ ដោយផ្អែកលើឯកសារពាក់ព័ន្ធចេញដោយស្ថាប័នជំនាញ សម្រាប់ជាមូលដ្ឋានក្នុងការកំណត់ប្រាក់ពន្ធ។ ដូច្នេះ ករណីខុសឆ្គងបែបនេះ គឺមិនមែនកើតឡើងដោយសារភ្នាក់ងារប្រមូលប្រាក់ពន្ធ ឬមន្ត្រីពន្ធដារអនុវត្តការងារមិនបានត្រឹមត្រូវ ឬមានការឃុបឃិតជាមួយអ្នកជាប់ពន្ធ ដូចការលើកឡើងនោះទេ។ នេះដោយសារតែម្ចាស់រថយន្តម៉ាក TOYOTA HIACE ពាក់ស្លាកលេខ សៀមរាប 2B-9906 រូបនោះ បានប្រកាសក្នុងលិខិតប្រកាសបង់ពន្ធ ថាជាប្រភេទរថយន្តដឹកទំនិញធុនតូច PICK UP ទៅតាមប័ណ្ណសម្គាល់យានយន្តដែលផ្តល់ដោយមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តសៀមរាប។

ម្យ៉ាងទៀត ភ្នាក់ងារប្រមូលប្រាក់ពន្ធ ដូចជាធនាគារ អេស៊ីលីដា ភីអិលស៊ី ជាដើម មិនមែនជាអង្គភាពកំណត់ពន្ធនោះទេ គឺអគ្គនាយកដ្ឋានពន្ធដារតែមួយគត់ដែលជាអង្គភាពកំណត់ប្រាក់ពន្ធ ដោយឈរលើមូលដ្ឋានទិន្នន័យនៅលើប័ណ្ណសម្គាល់យានយន្តចេញដោយក្រសួងសាធារណការនិងដឹកជញ្ជូន និងបានបង្កើតកម្មវិធីគណនាប្រាក់ពន្ធជាស្វ័យប្រវត្តិតាមប្រព័ន្ធកុំព្យូទ័រ សម្រាប់ធនាគារប្រើប្រាស់ក្នុងការប្រមូលប្រាក់ពន្ធ។ ដូច្នេះ រាល់កំហុសឆ្គងទាំងឡាយពាក់ព័ន្ធនឹងទិន្នន័យរបស់រថយន្តដែលនាំទៅដល់ការកំណត់ប្រាក់ពន្ធខុស ម្ចាស់រថយន្តត្រូវសហការជាមួយក្រសួងសាធារណការនិងដឹកជញ្ជូន ដើម្បីធ្វើការកែតម្រូវឡើងវិញ។

ទន្ទឹមនឹងនេះ អគ្គនាយកដ្ឋានពន្ធដារបានស្នើភ្នាក់ប្រមូលប្រាក់ពន្ធដើម្បីទាក់ទងម្ចាស់រថយន្តខាងលើ ឲ្យធ្វើការកែតម្រូវទិន្នន័យរថយន្តរបស់ខ្លួន និងប្រកាសបង់ពន្ធឡើងវិញ ស្របតាមច្បាប់។

អាស្រ័យហេតុនេះ សូមសាធារណជន បណ្តាញទំនាក់ទំនងសង្គម ក៏ដូចជាសារព័ត៌មាននានា មេត្តាជ្រាបជាព័ត៌មាន។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ០១៦

**អគ្គនាយកដ្ឋានពន្ធដារ**